**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០៩៤២/១៩ សរណ.ជ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកែសម្រួលខ្សែរត់រថយន្តក្រុង របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា ក្នុងគម្រោងធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈរថយន្តក្រុង នៅក្នុងរាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញ បានអនុញ្ញាតឱ្យរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ JICA ដាក់ឱ្យដំណើរការសេវាដឹកជញ្ជូនសាធារណៈជូនបងប្អូនប្រជាពលរដ្ឋចំនួន ១៣ខ្សែ ប្រើប្រាស់រថយន្តក្រុងចំនួន ២៣៥ គ្រឿង និងមានប្រជាពលរដ្ឋគាំទ្រប្រើប្រាស់សេវានេះ ពី ២៦,០០០ នាក់ ទៅ ៣០,០០០ នាក់ ក្នុងមួយថ្ងៃ ។

ទន្ទឹមនឹងការរីកចម្រើនខាងលើនេះ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើងថែមទៀត និងធានាបាននូវប្រសិទ្ធភាព នៃកិច្ចប្រតិបត្តិការសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងនេះ រដ្ឋបាលរាជធានីភ្នំពេញ អនុញ្ញាតឱ្យរដ្ឋាករ និងក្រុមជំនាញការ JICA ធ្វើការកែសម្រួលខ្សែរត់ចាស់មួយចំនួនដូចខាងក្រោម៖

១. ខ្សែទី១B : ដែលពីមុនរត់ចេញពីចំណតច្បារអំពៅ រហូតដល់ផ្សារតគីរ ត្រូវបានកែសម្រួលឱ្យរត់ចេញពីចំណតបឹងឈូកទៅផ្សារតគីរ ( វិលជុំ ) វិញ។

២. ខ្សែទី៥ : បច្ចុប្បន្នរត់ពីស្ថានីយចំណតរថយន្តក្រុងព្រែកព្នៅ កាត់តាមផ្សារអ៊ីអន២ ដល់ផ្សារអ៊ីអន១ ត្រូវបានកាត់ជាពីរខ្សែ ដោយខ្សែទី៥A រត់ចេញពីស្ថានីយចំណតរថយន្តក្រុងព្រែកព្នៅ ដល់ផ្សារអ៊ីអន២ (វិលជុំ ) និងខ្សែទី៥B រត់ពីផ្សារអ៊ីអន១ ដល់ផ្សារអ៊ីអន២ (វិលជុំ )។ ចំពោះការបង់ថ្លៃសេវាគឺអ្នកជិះបង់តែមួយលើក ដោយគ្រាន់តែបង្ហាញកន្ទុយសំបុត្រលើកទី១ ដល់ភ្នាក់ងារបម្រើសេវារបស់រដ្ឋាករ។

៣. ខ្សែទី១០ : ដែលពីមុនរត់ចេញពីផ្សារស៊ិនជូវីផ្លាហ្សា ដល់ចំណតបឹងឈូកត្រូវបានកែសម្រួលឱ្យរត់ចេញពីស្ថានីយចំណតរថយន្តក្រុងផ្លូវ២០០៤ ជាប់របងបញ្ជាការដ្ឋានកងទ័ពអាកាស ដល់ច្បារអំពៅរួចវិលត្រលប់មកវិញ។

៤. ខ្សែទី១៣ : ពីមុនរត់ចេញពីចំណតរង្វង់មូលក្បាលកាណុង ទៅដល់រង្វង់មូលផ្សារដើមថ្កូវ (វិលជុំ ) ត្រូវបានកែសម្រួលឱ្យរត់ចេញពីចំណតរាជាយស្ម័យយាន ទៅដល់រង្វង់មូលផ្សារដើមថ្កូវ (វិលជុំ ) វិញ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋមេត្តាជ្រាប និងចូលរួមធ្វើដំណើរតាមរថយន្តក្រុងសាធារណៈ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ប្រកបដោយសុវត្ថិភាព និងជាសុភភាព៕

ថ្ងៃ ច័ន្ទ ៨រោច ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ខែ តុលា ឆ្នាំ២០១៩
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

***កន្លែងទទួល៖***
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
  - «ដើម្បីគោរពជូនជ្រាប»
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង(City Bus)រាជធានីភ្នំពេញ
  - «ដើម្បីអនុវត្ត»
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  - «ដើម្បីជួយផ្សព្វផ្សាយ»
- ឯកសារ-កាលប្បវត្តិ